**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋាននីតិកម្មនៃក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតនាយកដ្ឋាននីតិកម្មចំណុះអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដើម្បីបំពេញបន្ថែមអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល។

**មាត្រា ២.-**

នាយកដ្ឋាននីតិកម្មមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ជាសេនាធិការរបស់ក្រសួងសុខាភិបាល ក្នុងកិច្ចការនីតិកម្ម
- កសាង រៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយផ្សេងៗទាក់ទងនឹងវិស័យសុខាភិបាល ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- ពិនិត្យ ផ្តល់យោបល់ និងកែសម្រួលសេចក្តីព្រាងច្បាប់ អត្ថបទច្បាប់ លិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងសុខាភិបាល
- បណ្តុះបណ្តាលនិងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយជាធរមានទាក់ទងនឹងវិស័យសុខាភិបាល
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យសុខាភិបាល
- សហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការអង្កេតនូវរាល់ការអនុវត្តច្បាប់ទាក់ទងនឹងវិស័យសុខាភិបាល
- រៀបចំសំណុំឯកសារក្នុងកិច្ចដំណើរការដោះស្រាយវិវាទដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាលតាមផ្លូវច្បាប់និងនីតិវិធីទៅតុលាការដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- គ្រប់គ្រងបណ្ណាល័យរបស់ក្រសួងនិងធ្វើការចែកផ្សាយសៀវភៅរាជកិច្ច
- ចងក្រងនិងតម្កល់ឯកសារច្បាប់ លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាល
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ជូនថ្នាក់ដឹកនាំក្រសួងសុខាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងសុខាភិបាលប្រគល់ជូន។

**មាត្រា ៣.-**

នាយកដ្ឋាននីតិកម្មដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនតាមការចាំបាច់។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យដែលចំណុះនាយកដ្ឋាននីតិកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ដើម្បីស្នើសុំចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**វេជ្ជបណ្ឌិត ម៉ម ប៊ុនហេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ